**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**អគ្គលេខាធិការដ្ឋាន**

-លេខ: ៣៦៣/២០ អ.ល.រ.ស.សជសា.ផព

# សេចក្តីជូនដំណឹង

*****

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិ មេត្តាជ្រាបថា សម័យប្រជុំលើកទី៣ នីតិកាលទី៦ បានបិទនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២០ ហើយ រហូតមកដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ មានរយៈបីខែ។ **កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០២០ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានសម្រេចបើកសម័យប្រជុំរដ្ឋសភា លើកទី៤ នីតិកាលទី ៦ នៅថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំជូត ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០។**

ក្នុងចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៣ និងលើកទី៤ នីតិកាលទី៦ រយៈពេលបីខែនេះ ថ្នាក់ដឹកនាំរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា គណៈកម្មការនានា និងសមាជិក សមាជិការដ្ឋសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី និងភារកិច្ច រួមមាន បើកសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ចំនួន ៣លើក ដើម្បីពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ចំនួន ៩ និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលចំនួន ៩រូប បំពេញការងារការទូតសភា និងចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមមូលដ្ឋាន ដើម្បីចូលរួមដោះស្រាយនូវសំណូមពរផ្សេងៗ ដែលមានខ្លឹមសារដូចមានចែងក្នុងរបាយការណ៍របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្តីពីសកម្មភាពរបស់រដ្ឋសភាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៣ និងលើកទី៤ នីតិកាលទី៦ ។

នៅក្នុងឱកាសបើកសម័យប្រជុំរដ្ឋសភាខាងលើ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** បានប្រោសប្រទាននូវព្រះរាជសារជូនសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៦ ផងដែរ ។

ដើម្បីរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមអនុវត្តនូវវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ការណែនាំរបស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក (WHO) គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានសម្រេចមិនអញ្ជើញតំណាងរាស្ត្រ និងភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ចូលរួមក្នុងពិធីបើកសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ខាងលើទេ ។ ដើម្បីរាយការណ៍ជូនអង្គសភា និងសាធារណជនជាតិនិងអន្តរជាតិ បានជ្រាបពីសកម្មភាពសំខាន់ៗរបស់រដ្ឋសភា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការផ្សព្វផ្សាយនូវ

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@nac.org.kh គេហទំព័រ: www.nac.org.kh

ព្រះរាជសារព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងរបាយការណ៍របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្តីពីសកម្មភាពរបស់រដ្ឋសភាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៣ និងលើកទី ៤ នីតិកាលទី ៦ ខាងលើតាមរយៈ ៖

- គេហទំព័ររបស់រដ្ឋសភា http://nac.org.kh
- ទូរទស្សន៍ជាតិកម្ពុជា និងវិទ្យុជាតិកម្ពុជា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជាតិ និងអន្តរជាតិ មេត្តាជ្រាប ។

ថ្ងៃពុធ ៩កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី ១ ខែមេសា ឆ្នាំ២០២០

**អគ្គលេខាធិការ** ៥៥

ឡេង ប៉េងឡុង

**ចម្លងជូន** :

- តំណាងរាស្ត្រ
- គ្រប់ក្រសួង- ស្ថាប័ន

"ដើម្បីជូនជ្រាប "